# ៤. បំនិនជីវិត

៤.១. ការបង្រៀន **បំនិនជីវិត** មានតួនាទីមួយយ៉ាងសំខាន់ក្នុងចំនោមតួនាទីជាច្រើនរបស់សាលារៀន។ ក្នុងគោល នយោបាយនេះ **បំនិនជីវិត** ត្រូវកំនត់ថាជា *បំនិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និង វិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើសេចក្តីសំរេចចិត្ត អាចធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និង អាចដោះស្រាយនិងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំនិនដែលរួមចំនែកក្នុងការលើកស្ទួយសុខុមាលភាព និង ជីវិតប្រកបដោយផលិតភាព* ។

៤.២ មូលដ្ឋានដ៏រឹងមាំបំផុតនៃ **បំនិនជីវិត** គឺ ការចេះអានអក្សរខ្មែរ ចេះគណនាលេខ ហើយការបង្រៀនបំនិនទាំងនេះជាគោលបំនងនៃការអប់រំបឋមសិក្សានៅបីថ្នាក់ដំបូង។

៤.៣ ស្របជាមួយគោលនយោបាយដែលបានចែងក្នុង **ការអប់រំសំរាប់ទាំងអស់គ្នា**(ទំព័រ៥៩) **កម្មវិធីសិក្សាជាតិ** នឹងបញ្ចូលការបង្រៀន **បំនិនជីវិត**ក្នុងមុខវិជ្ជានីមួយៗ ។ ការអភិវឌ្ឍសៀវភៅសិក្សាតាមមុខវិជ្ជានីមួយៗ ត្រូវបញ្ចូល ខ្លឹមសារ និងសកម្មភាព ដែលផ្តោតទៅលើការបង្រៀនបំនិនជីវិតផ្សារភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ ។

៤.៤ ផ្អែកតាមគោលនយោបាយ **ការអប់រំសំរាប់ទាំងអស់គ្នា** (ទំព័រ ៦០ ) សាលារៀនទាំងឡាយនឹងសង្ឃឹមថា មានការអភិវឌ្ឍភាពជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋា ភិបាល ដោយផ្តល់បន្ថែមនូវកម្មវិធី **បំនិនជីវិតតាមមូលដ្ឋាន** ដើម្បីអោយសិស្សទទួលបាននូវការសិក្សា **បំនិនជីវិត**ពិសេសៗ ដែលមានក្នុងមូលដ្ឋានរបស់ខ្លួន ។ ប្រសិនបើមានលទ្ធភាពសាលារៀនអាចបណ្តុះបណ្តាល បំនិនវិជ្ជាជីវៈបន្ថែមទៀត។